សេចក្តីព្រាង

# ច្បាប់

# ស្តីពី

# វិសោធនកម្មមាត្រា ២៤៦ មាត្រា ២៥៥ មាត្រា ២៦៦ មាត្រា ៣២០ និងមាត្រា ៤៨៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី

មាត្រា តែមួយ៖ មាត្រា ២៤៦ (គោលការណ៍នៃការបញ្ជូនដោយឆន្ទានុសិទ្ធិ ជាអាទិ៍) មាត្រា ២៥៥ (ល័ក្ខខ័ណ្ឌដើម្បីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ) មាត្រា ២៦៦ (សិទ្ធិពិនិត្យពាក្យបណ្ដឹងឧទ្ធរណ៍របស់តុលាការនៃបណ្ដឹងឧទ្ធរណ៍) មាត្រា ៣២០ (ពាក្យសុំឲ្យចេញដីកាសម្រេចដាស់តឿន) និងមាត្រា ៤៨៨(ការរៀបចំការចែកចំណែក) នៃក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានកែប្រែដូចតទៅ៖

**មាត្រា ២៤៦ ថ្មី** - គោលការណ៍នៃការបញ្ជូនដោយឆន្ទានុសិទ្ធិ ជាអាទិ៍

១-ការបញ្ជូនត្រូវធ្វើដោយឆន្ទានុសិទ្ធិ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់។

២-កិច្ចការបញ្ជូនត្រូវធ្វើឡើងដោយក្រឡាបញ្ជី។

៣-ការបញ្ជូនត្រូវបានប្រតិបត្តិដោយបុគ្គលិកប្រៃសណីយ៍ អាជ្ញាសាលា ឬក្រឡាបញ្ជី។

៤-ក្នុងករណី ការបញ្ជូនមិនអាចប្រតិបត្តិបានតាមកថាខណ្ឌទី ៣ ខាងលើនេះ នោះការបញ្ជូនអាចត្រូវបានប្រតិបត្តិដោយអាជ្ញាធររដ្ឋបាល ឬតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។

**មាត្រា ២៥៥ ថ្មី** - ល័ក្ខខ័ណ្ឌដើម្បីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ

១-ក្នុងករណីដូចខាងក្រោមនេះ ក្រឡាបញ្ជីអាចធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបាន តាមពាក្យសុំ ដោយទទួលការអនុញ្ញាតពីតុលាការ៖

ក-ទោះបីបានខំប្រឹងប្រែងធ្វើការស្រាវជ្រាវរកលំនៅឋាន ឬទីសំណាក់របស់កាគី ឬកន្លែងផ្សេងទៀត ដែលត្រូវធ្វើការបញ្ជូនក៏ដោយ ក៏នៅតែរកមិនឃើញ។

ខ-មិនអាចបញ្ជូន តាមបញ្ញត្តិនៃមាត្រា ២៥២ (ការបញ្ជូនបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោល) នៃក្រមនេះ។

គ-មិនអាចធ្វើការបញ្ជូន តាមបញ្ញត្តិនៃមាត្រា ២៥៣ (ការបញ្ជូនដែលត្រូវធ្វើនៅបរទេស) នៃក្រមនេះបាន ឬត្រូវបានទទួលស្គាល់ថា គ្មានលទ្ធភាពនឹងធ្វើបានតាមបញ្ញត្តិនោះ ក្នុងករណីដែលត្រូវធ្វើការបញ្ជូននៅបរទេស។

ឃ-បានធ្វើការបញ្ជូនដោយប្រគល់ឲ្យក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចនៅបរទេសឲ្យធ្វើតាមបញ្ញត្តិនៃមាត្រា ២៥៣ (ការបញ្ជូនដែលត្រូវធ្វើនៅបរទេស) នៃក្រមនេះ តែមិនបានទទួលលិខិតបញ្ជាក់អំពីការបញ្ជូននោះ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ចាប់តាំងពីពេលបញ្ជូននោះ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើយល់ឃើញថាចាំបាច់ ដើម្បីជៀសវាងការយឺតយ៉ាវក្នុងដំណើរការនីតិវិធី តុលាការអាចបង្គាប់ឲ្យក្រឡាបញ្ជីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបាន ទោះបីជាគ្មានពាក្យសុំក៏ដោយ។

ក-ការទាមទារចំពោះបុគ្គលដែលមានទីស្នាក់ការ ឬកន្លែងអាជីវកម្ម ហើយការទាមទារនោះ ទាក់ទងនឹងការងារនៃទីស្នាក់ការ ឬទីកន្លែងអាជីវកម្មនោះ៖ កន្លែងដែលមានទីស្នាក់ការ ឬទីកន្លែងអាជីវកម្មនោះ។

ខ-ការទាមទារឲ្យសងជាប្រាក់ដោយរូបិយាណត្តិ ឬមូលប្បទានប័ត្រ និងការទាមទារបន្ទាប់បន្សំដែលទាក់ទងនឹងវត្ថុទាំងនេះ៖ កន្លែងដែលត្រូវសងរូបិយាណត្តិ ឬមូលប្បទានប័ត្រនោះ។

៣-សមត្ថកិច្ចដែលកំណត់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ឬកថាខណ្ឌទី ២ ខាងលើនេះ គឺជាសមត្ថកិច្ចផ្តាច់មុខ។

**មាត្រា ៤៨៨ ថ្មី** - ការរៀបចំការចែកចំណែក

១-បើមានមូលហេតុដែលចែងនៅចំណុចនីមួយៗ ខាងក្រោម តុលាការដែលត្រូវចែកចំណែកត្រូវកំណត់កាលបរិច្ឆេទនៃការចែកចំណែក ហើយផ្តល់ដំណឹងអំពីពេលវេលា និងទីកន្លែងនោះ ទៅម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែក និងកូនបំណុល៖

ក-ក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ពេលដែលមូលហេតុនៃការធ្វើប្រាក់បានរលត់ ក្នុងករណីដែលមានការជូនដំណឹងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៤០០ (ការធ្វើប្រាក់ទុកនៅតុលាការដោយអាជ្ញាសាលា) ឬពេលដែលមានការជូនដំណឹងតាមបញ្ញត្តិនៃមាត្រា ៤០១ (ការជូនដំណឹងទៅសាលាដំបូង) នៃក្រមនេះ។

ខ-ក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ពេលដែលបានធ្វើការធ្វើប្រាក់ តាមបញ្ញត្តិនៃកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃមាត្រា ៤១១ (ការធ្វើប្រាក់ទុកដោយកូនបំណុលទី ៣) និងមាត្រា ៤១២ (បណ្តឹងទាមទារប្រមូលបំណុល) ឬពេលដែលបានធ្វើការលក់ដោយដីកាសម្រេចបង្គាប់ឲ្យលក់ តាមបញ្ញត្តិនៃមាត្រា ៤១៣ (ដីកាសម្រេចបង្គាប់ឲ្យលក់) ឬពេលដែលប្រាក់ដែលបានមកពីការលក់ ត្រូវបានប្រគល់ តាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រា ៤១៤ (ការអនុវត្តដីកាសម្រេចរឹបអូសសិទ្ធិទាមទារឲ្យប្រគល់ចលនវត្ថុ) នៃក្រមនេះ។

គ-ក្នុងការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ពេលដែលមានការបង់ថ្លៃលក់តាមបញ្ញត្តិនៃមាត្រា ៤៤៧ (ការបង់ថ្លៃលក់) ឬពេលដែលដីកាសម្រេចអនុញ្ញាតឲ្យលក់ បានចូលជាស្ថាពរ នៅក្នុងករណីដែលមានការស្នើសុំ ដោយយោងតាមបញ្ញត្តិនៃវាក្យខណ្ឌទី ១ កថាខណ្ឌទី ៣ មាត្រា៤៤៧ (ការបង់ថ្លៃលក់) នៃក្រមនេះ។

ឃ-ក្នុងការអនុវត្តដោយបង្ខំចំពោះនាវា ពេលដែលមានការបង់ថ្លៃលក់ ដោយយោងតាមបញ្ញត្តិនៃមាត្រា ៤៧៩ (ការបង់ថ្លៃលក់) នៃក្រមនេះ។

២-នៅពេលដែលកាលបរិច្ឆេទនៃការចែកចំណែកត្រូវបានកំណត់ហើយ ក្រឡាបញ្ជីត្រូវដាស់តឿនម្ចាស់បំណុលម្នាក់ៗ ឲ្យផ្តល់លិខិតគណនាអំពីប្រាក់ដើមនៃសិទ្ធិលើបំណុល ការប្រាក់ រហូតដល់កាលបរិច្ឆេទនៃការចែកចំណែក និងសោហ៊ុយសម្រាប់ការអនុវត្ត ទៅតុលាការដែលត្រូវចែកចំណែក ក្នុងអំឡុងពេល ១ (មួយ) សប្តាហ៍។